**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**ធនាគារជាតិ នៃ កម្ពុជា**

លេខ ធ៧-០៩-០៤៣ ប្រ.ក

# ប្រកាស

## ស្តីពី

## ការបង្កើតក្រុមការងារ

## នៃគណៈកម្មាធិការដឹកនាំការងារកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ

## ទេសាភិបាល ធនាគារជាតិនៃកម្ពុជា

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/២៧ ចុះថ្ងៃទី២៦ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃធនាគារជាតិនៃកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៤/២៤៤ ចុះថ្ងៃទី០៧ ខែកញ្ញា ឆ្នាំ២០០៤ ស្តីពីការតែងតាំង ឯកឧត្តម **ជា ចាន់តូ** ជាអគ្គទេសាភិបាលធនាគារជាតិនៃកម្ពុជា មានឋានៈស្មើទេសរដ្ឋមន្ត្រី
- បានឃើញអនុក្រឹត្យលេខ ១៣៥ អនក្រ.បក ចុះថ្ងៃទី២១ ខែកញ្ញា ឆ្នាំ២០០៧ ស្តីពីការកែសំរួលការរៀបចំ និង ការប្រព្រឹត្តទៅនៃគណៈកម្មាធិការគោលនយោបាយសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- បានឃើញសេចក្តីសម្រេចលេខ ៥៦ សសរ ចុះថ្ងៃទី៣០ ខែតុលា ឆ្នាំ២០០៧ ស្តីពីការបង្កើតគណៈកម្មាធិការដឹក នាំការងារកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ
- យោងតាមការចាំបាច់របស់ធនាគារជាតិនៃកម្ពុជា

## សំរេច

**ប្រការ១.-** បង្កើត "ក្រុមការងារគណៈកម្មាធិការដឹកនាំការងារកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ" ដែលហៅកាត់ "លគហស" ដែលរួមមានសមាសភាពដូចខាងក្រោម :

| | | |
|---|---|---|
| ១- លោកជំទាវ នាវ ច័ន្ទថាណា | ទេសាភិបាលរង | ប្រធាន |
| ២- លោក ប៉ាល់ ប៊ុយបុណ្ណាង | អគ្គពិនិត្យ | អនុប្រធាន |
| ៣- លោក អ៊ូ ចាន់តារា | ប្រធាននាយកដ្ឋានគណនេយ្យ | សមាជិក |
| ៤- លោក ជា ចិន្ត្រា | ប្រធាននាយកដ្ឋានបោះផ្សាយ-ឃ្លាំងបេឡា | សមាជិក |
| ៥- លោកស្រី ងួន សុខា | ប្រធាននាយកដ្ឋានស្រាវជ្រាវសេដ្ឋកិច្ចនិងស្ថិតិ | សមាជិក |
| ៦- លោកស្រី គាំ គណ្ឋា | ប្រធាននាយកដ្ឋានប្រតិបត្តិការ | សមាជិក |



ប្រអប់សំបុត្រលេខ ២៥, ផ្ទះលេខ ២២-២៤ មហាវិថី ព្រះនរោត្តម រាជធានីភ្នំពេញ, ទូរស័ព្ទ : (៨៥៥-២៣) ៧២២ ៥៦៣, ទូរស័ព្ទ . ទូរសារ : (៨៥៥-២៣) ៤២៦ ១១៧

**ប្រការ២.-** ក្រុមការងារគណៈកម្មាធិការដឹកនាំការងារកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ មានមុខងារ និងភារកិច្ច ដូចតទៅ ៖

- ធ្វើជាសេនាធិការបច្ចេកទេសរបស់គណៈកម្មាធិការដឹកនាំការងារកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ និងគណៈកម្មការកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈក្នុងការរៀបចំ និងតាមដានការអនុវត្តកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ។
- ធ្វើជាចំណុចប្រមូលផ្តុំ ក្នុងការផ្តល់ប្រឹក្សា ផ្តល់ការសំរបសំរួល និងផ្តល់ការណែនាំផ្សេងៗពាក់ព័ន្ធនឹងការរៀបចំ និងការតាមដានត្រួតពិនិត្យ ការអនុវត្តកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈជាមួយគ្រប់ក្រសួង ស្ថាប័ន ពិសេសក្រុមការងារកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈព្រមទាំង នាយកដ្ឋាន និងអង្គភាពនានាក្រោមឱវាទក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ។
- បូកសរុបរបាយការណ៍ពីគ្រប់ក្រុមការងារកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈនៅធនាគារជាតិនៃកម្ពុជា សំរាប់ជូនទៅគណៈកម្មាធិការដឹកនាំការងារកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ។

**ប្រការ៣.-** អគ្គលេខាធិការដ្ឋាន អគ្គនាយកដ្ឋាន អគ្គាធិការដ្ឋាន អគ្គបេឡា និងអង្គភាពពាក់ព័ន្ធ ព្រមទាំងសាមីខ្លួន មានភារកិច្ចអនុវត្តប្រកាសនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ ថ្ងៃទី ១៣ ខែមីនា ឆ្នាំ២០០៨

**ទេសាភិបាល**

ជា-ចាន់តូ

**ចម្លងជូន ៖**

- ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- សាមីខ្លួន ដើម្បីអនុវត្ត
- កាលប្បវត្តិ ឯកសារ